Fact Sheet 1 - Khmer

សន្លឹកហេតុការណ៍ 1

# ការទទួលស្គាល់អំពើហិង្សាលើដៃគូស្និទ្ធស្នាល ក្នុងគ្រួសារ និងលើផ្លូវភេទ

ស្ត្រី និងកូនៗរបស់ពួកគេ អាចទទួលរងទម្រង់ផ្សេងៗនៃឥរិយាបទឃោរឃៅ និងការរំលោភបំពាន។ ស្ថិតិបង្ហាញថា ឥរិយាបថនេះត្រូវបានប្រព្រឹត្តជាលើសលប់ដោយបុរស។

**ដើម្បីជួយអ្នកក្នុងការកំណត់អត្តសញ្ញាណ គាំទ្រ និងឆ្លើយតបយ៉ាងប្រសិទ្ធិភាពចំពោះបុគ្គល និងក្រុមគ្រួសារដែលអាចទទួលរងនូវអំពើហិង្សាលើដៃគូស្និទ្ធស្នាល ក្នុងគ្រួសារ និងលើផ្លូវភេទ (DFSV) វាសំខាន់ណាស់ដែលត្រូវដឹងថា តើវាជាអ្វី និងអ្វីដែលអ្នកអាចធ្វើបានដើម្បីជួយ។**

## តើអំពើហិង្សាលើដៃគូស្និទ្ធស្នាល ក្នុងគ្រួសារ និងលើផ្លូវភេទ (DFSV) ជាអ្វី ?

អំពើហិង្សាលើដៃគូស្និទ្ធស្នាល និងក្នុងគ្រួសារ គឺជាអាកប្បកិរិយារំលោភបំពានធ្វើឡើងដោយដៃគូម្នាក់ ដៃគូអតីតកាល នរណាដែលជនរងគ្រោះស្ថិតក្នុងទំនាក់ទំនងជិតស្និទ្ធជាមួយ ឬពីសមាជិកគ្រួសាររបស់នាង រួមទាំងមនុស្សច្រើនជំនាន់ ដែលត្រូវបានប្រើដើម្បីគ្រប់គ្រង ឬបំភិតបំភ័យជនរងគ្រោះ។

## វាមិនត្រឹមតែជារាងកាយប៉ុណ្ណោះទេ

អំពើហិង្សាលើដៃគូស្និទ្ធស្នាល អាចរួមមាន៖

- អំពើហិង្សាលើរាងកាយបណ្តាលឱ្យរងរបួស - ការវាយដំ ការខាំ ការរុញច្រាន ការទាត់ធាក់ ការច្របាច់ក
- អំពើហិង្សាខាងផ្លូវភេទ - ការបង្ខំឱ្យនរណាម្នាក់រួមភេទ។ វាអាចរាប់បញ្ចូលទាំងការចាប់រំលោភ និងការរំលោភបំពានខាងផ្លូវភេទ ស្មន្ធការ និងការរំលោភបំពានផ្លូវភេទលើកុមារ
- ការរំលោភបំពានលើអារម្មណ៍ ឬផ្លូវចិត្ត - ការជេរប្រមាថ ឬធ្វើឱ្យដៃគូអាម៉ាស់ជាសាធារណៈ
- ការរំលោភបំពានដោយពាក្យសំដី - ការស្រែកដាក់ ការជេរប្រមាថ ឬការរិះគន់ដៃគូជានិច្ច
- ការរំលោភបំពានខាងសង្គម - ការដាក់ឱ្យនៅដាច់ពីគេ និងការទប់ស្កាត់នរណាម្នាក់មិនឱ្យជួបមិត្តភក្តិ និងក្រុមគ្រួសារ
- ការរំលោភបំពានផ្លូវវិញ្ញាណ - ការបដិសេធ ឬប្រើជំនឿ និងការអនុវត្តខាងផ្លូវសាសនាដើម្បីគ្រប់គ្រង និងត្រួតត្រានរណាម្នាក់
- ការបំផ្លាញទ្រព្យសម្បត្តិ - ដើម្បីគ្រប់គ្រង បំភិតបំភ័យ គំរាមកំហែង ឬបន្ទាបបន្ថោក
- ការរំលោភបំពានហិរញ្ញវត្ថុ - ការគ្រប់គ្រងហិរញ្ញវត្ថុ ឬបដិសេធចំពោះប្រាក់កាសចាំបាច់
- ការគំរាមគំហែងធ្វើឱ្យឈឺចាប់ - រួមទាំងសត្វចិញ្ចឹម និងកុមារ
- ការឈ្លបចាប់ - ការដេញតាមនរណាម្នាក់ប្រឆាំងនឹងឆន្ទៈរបស់ពួកគេ ដោយផ្ទាល់ ឬតាមអ៊ីនធឺណិត
- ការរំខានយាយីលើផ្លូវភេទ និងការបំភិតបំភ័យនៅកន្លែងធ្វើការ និងនៅទីសាធារណៈ
- ការកាត់ស្បែកចុងប្រដាប់បន្តពូជស្ត្រី
- អាពាហ៍ពិពាហ៍ដោយបង្ខំ និងអាពាហ៍ពិពាហ៍កុមារ
- បទឧក្រិដ្ឋដែលគេហៅថា ‘ជាកិត្តិយស’ - ពាក់ព័ន្ធនឹងអំពើហិង្សា និងការបំភិតបំភ័យដើម្បីគ្រប់គ្រងស្ត្រីដោយផ្អែកលើការយល់ឃើញថា នាងបានប្រព្រឹត្តតាមរបៀបមួយដែលនាំមកនូវភាពអាម៉ាស់ដល់ក្រុមគ្រួសារ
- ការរំលោភបំពានទាក់ទងនឹងបណ្ណាការ - ជាជំនូនបណ្ណាការដែលត្រូវបានគិតថាមិនពេញចិត្តពីកូនកំលោះ និង/ឬគ្រួសាររបស់គាត់។ វាអាចបណ្តាលឱ្យមានការបៀតបៀនយាយីកូនក្រមុំមុនពេល ក្នុងអំឡុងពេល និងក្រោយពេលរៀបការ ហើយការរំលោភបំពាន និងអំពើហិង្សាដើម្បីជំរិតទារថ្លៃបណ្ណាការដែលកើនឡើង។ ក្នុងករណីធ្ងន់ធ្ងរ វាអាចបណ្តាលឱ្យស្លាប់។

## ក្រោមច្បាប់

មនុស្សគ្រប់រូបមានសិទ្ធិរស់នៅប្រកបដោយសុវត្ថិភាព និងទទួលបានការគោរព។ ច្បាប់នៅប្រទេសអូស្ត្រាលីអនុវត្តចំពោះបុរស និងស្ត្រីស្មើៗគ្នា។ DFSV មិនទទួលយកបានទេ ហើយវាជាបទឧក្រិដ្ឋកម្មប្រឆាំងនឹងច្បាប់។

នៅរដ្ឋអូស្ត្រាលីខាងត្បូង តាមច្បាប់ ជនល្មើស DFSV អាចត្រូវបានជាប់ការចោទប្រកាន់ពីបទរំលោភបំពាន ឬប្រសិនបើនាំឱ្យមានការរងរបួស ដែលបណ្តាលឱ្យមានការឈឺចាប់។

## តើខ្ញុំអាចដឹងដោយរបៀបណា ប្រសិនបើនរណាម្នាក់កំពុងទទួលរងនូវ DFSV ?

DFSV កំពុងតែធ្វើឱ្យខូចខាតដល់ជនរងគ្រោះ កុមារ គ្រួសារ និងមិត្តភក្តិរបស់ពួកគេ។ វាអាចកើតឡើងចំពោះនរណាម្នាក់ ដោយមិនគិតពីអាយុ វណ្ណៈ និន្នាការភេទ សមត្ថភាព ពូជសាសន៍ ភេទ ឬសាសនា។

សញ្ញាមួយចំនួនដែលស្ត្រីម្នាក់កំពុងទទួលរងនូវ DFSV រួមមាន៖

- ការឈប់ចេញទៅក្រៅដោយគ្មានហេតុផល
- ការព្រួយបារម្ភច្រើនអំពីការធ្វើឱ្យមនុស្សម្នាក់ខឹង
- បង្កើតលេសជាច្រើនសម្រាប់ឥរិយាបទអវិជ្ជមានរបស់នរណាម្នាក់
- មានស្លាកស្នាម ឬស្នាមរបួសនៅលើរាងកាយរបស់នាង ដែលមិនអាចពន្យល់បាន
- ឈប់ចំណាយពេលជាមួយមិត្តភក្តិ និងក្រុមគ្រួសារ
- មើលទៅដូចជាភ័យខ្លាច ឬប្រយ័ត្នចំពោះមនុស្សជាក់លាក់ម្នាក់
- មើលទៅដូចជាមានការព្រួយបារម្ភ ថាពួកគេតាមដាន ឬត្រួតត្រាតាមរបៀបណាមួយ។

## តើមានសញ្ញានៃអាកប្បកិរិយាហិង្សា ឬរំលោភបំពានអ្វីខ្លះ ?

ជនល្មើសនៃអំពើហិង្សា និងការរំលោភបំពានអាច៖

- ធ្វើតាមរបៀបដែលធ្វើឱ្យប្រពន្ធ/សង្សារស្រី/ដៃគូភ័យខ្លាច
- បន្ទាបបន្ថោកប្រពន្ធ/សង្សារស្រី/ដៃគូគ្រប់ពេល
- ធ្វើការគំរាមកំហែងធ្វើបាបប្រពន្ធ/សង្សារស្រី/ដៃគូ
- គ្រប់គ្រងប្រពន្ធ/សង្សារស្រី/ដៃគូ រួមទាំង៖
  - កន្លែងដែលពួកគេទៅ
  - អ្នកណាដែលពួកគេជួប និងនរណាដែលពួកគេនិយាយជាមួយ
  - តើមានអ្វីកើតឡើងចំពោះប្រាក់កាសរបស់ពួកគេ
  - របៀប និងពេលណាដែលពួកគេអាចប្រើទូរស័ព្ទ ឡាន ឬកុំព្យូទ័ររបស់ពួកគេ
  - របៀបដែលពួកគេត្រូវបានអនុញ្ញាតឱ្យមានឥរិយាបទដោយមានវិន័យជាច្រើន
  - ខឹងសម្បារ ប្រសិនបើនាងមិនធ្វើតាមវិន័យរបស់ពួកគេ។

## ការចាត់វិធានការបន្ទាប់

DFSV មិនអាចទទួលយកបានឡើយនៅក្នុងសហគមន៍ ឬវប្បធម៌ណាមួយ។ អ្នកអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការទប់ស្កាត់ និងដោះស្រាយបញ្ហា DFSV និងរក្សាស្ត្រី និងកុមារឱ្យមានសុវត្ថិភាព។

ដើម្បីឱ្យបានដឹងថាតើមាននរណាម្នាក់កំពុងទទួលរងនូវ DFSV ចូរចំណាយពេលស្តាប់ និងគាំទ្រពួកគេ។

ព័ត៌មានបន្ថែមអចទទួលយកបាននៅត្រង់
1800RESPECT (1800 737 732) ឬ
www.1800RESPECT.org.au

**ក្នុងករណីបន្ទាន់ ឬប្រសិនបើនរណាម្នាក់ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ សូមទូរស័ព្ទលេខ 000 ឱ្យបានភ្លាមៗ។**

នេះគឺជាផ្នែកមួយនៃសន្លឹកហេតុការណ៍ទាំង 4 ស្តីពី DFSV។ ព័ត៌មានបន្ថែមស្តីពីអ្វីដែលអ្នកអាចធ្វើបាន ដើម្បីជួយអ្នកណាម្នាក់ដែលកំពុងទទួលរងនូវ DFSV មាននៅក្នុងសន្លឹកហេតុការណ៍ 2។ ដើម្បីស្វែងយល់អំពីការលើកកម្ពស់សមភាពយេនឌ័រ និងការគោរព សូមមើលសន្លឹកហេតុការណ៍ 3 និង 4។